# I ទីស្តីការគណៈរដ្ឋមន្ត្រី

## ១— អនុក្រឹត្យ

រាជធានីភ្នំពេញ , ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦

**អនុក្រឹត្យ លេខ ៣៦ អនក្រ.បក**

**ស្តីពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ**

* * *

**រាជរដ្ឋាភិបាល**

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយក រដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២

–បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

–បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

–បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤–៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

–បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤–៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

–បានឃើញព្រះរាជក្រមលេខ នស.រកត ១៩៦–០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

–បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ

–តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

–តាមការយល់ព្រមនៃគណៈរដ្ឋមន្ត្រី

## សំរេច

**មាត្រា ១ :** ត្រូវបានបង្កើតអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដូចមានគំរូថែងក្នុងឧបសម្ព័ន្ធ នៃអនុក្រឹត្យ នេះ ។

**មាត្រា ២ :** អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ មានសុពលភាព ១០ ឆ្នាំ ចាប់ពីថ្ងៃចេញអត្តសញ្ញាណប័ណ្ណនេះ ។

**មាត្រា ៣ :** អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ អាចផ្តល់ជូនបានចំពោះតែ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុចាប់ពី ១៨ ឆ្នាំ ឡើងទៅ ។

**មាត្រា ៤ :** ក្នុងការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ អាជ្ញាធរមានសមត្ថកិច្ច ត្រូវពិនិត្យ ÷

- សំបុត្រកំណើត ឬ
- សាលក្រមរបស់តុលាការបញ្ជាក់ទទួលស្គាល់ថាជននោះកើតពីឪពុក ឬ ម្តាយដែលមានសញ្ជាតិខ្មែរ
- ព្រះរាជក្រឹត្យប្រកាសទទួលស្គាល់ការសុំទាមទារសញ្ជាតិខ្មែររបស់សាមីជន ឬ
- ព្រះរាជក្រឹត្យប្រកាសទទួលស្គាល់ការសុំចូលសញ្ជាតិខ្មែររបស់សាមីជន ឬ
- ឯកសារ ឬ ភស្តុតាងបញ្ជាក់ថាសាមីជន កើតនៅកម្ពុជា ពីឪពុក ឬ ម្តាយ ដែលកើតនៅកម្ពុជា ឬ
- ឯកសារ ឬ ភស្តុតាងបញ្ជាក់ថាសាមីជនធ្លាប់មានសញ្ជាតិខ្មែរ ឬ
- ឯកសារ ឬ ភស្តុតាងបញ្ជាក់ថាសាមីជន កើតពីឪពុក ឬ ម្តាយមានសញ្ជាតិខ្មែរ ឬ
- ឯកសារណាមួយ ដែលអាចបញ្ជាក់បានថា ជននោះជាប្រជាពលរដ្ឋខ្មែរ ។

ក្នុងការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ មន្ត្រីមានសមត្ថកិច្ច ត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនតាមទោសសប្បញ្ញត្តិ នៃច្បាប់ស្តីពីសញ្ជាតិ ក្នុងករណីដែលខ្លួនចេញអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរអោយជនណាម្នាក់ដែលពុំមានសញ្ជាតិខ្មែរ ។

**មាត្រា ៥ :** បែបបទនៃការសុំអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ក្នុងការទទួលស្គាល់ភស្តុតាងបញ្ជាក់អំពីសញ្ជាតិត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃដោយមានការយល់ព្រមពីរាជរដ្ឋាភិបាល ។

**មាត្រា ៦ :** មានតែ មន្ត្រីដែលមានមុខតំណែង អភិបាលខេត្ត ក្រុង ជាមន្ត្រីមានសមត្ថកិច្ចក្នុងការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

មន្ត្រីនេះមិនអាចផ្ទេរ ឬ ប្រគល់សិទ្ធិអំណាចនេះអោយមន្ត្រីម្នាក់ទៀតបានឡើយ ។

**មាត្រា ៧** : អ្នកសុំអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ត្រូវបង់អាករ តាមការកំណត់របស់ប្រកាសអន្តរក្រសួងមហាផ្ទៃ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ៨** : ថ្លៃអាករនេះត្រូវបង់ចូលថវិកាជាតិ ។

បែបបទនៃការប្រមូលអាករនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងមហាផ្ទៃ ។

**មាត្រា ៩** : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១០** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីមុខងារសាធារណៈ គ្រប់ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១
ព្រះហស្តលេខានិងត្រា
**នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី២
ហត្ថលេខានិងត្រា
**ហ៊ុន សែន**

បានបង្គំទូលថ្វាយ និង ជំរាបជូន
សម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១
និង សម្តេចនាយករដ្ឋមន្ត្រីទី ២
សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
**ស ខេង** **យូ ហុកគ្រី**

* * *

# ឧបសម្ព័ន្ធនៃអនុក្រឹត្យ ស្ដីពីការបង្កើតអត្តសញ្ញាណប័ណ្ណ សញ្ជាតិខ្មែរ




